# នយោបាយសុចរិតប្រាស់ចាកភាពអាត្មានិយម

នៅពេលគសប និយាយពាក្យពីរ ដែលមានន័យពាក់ព័ន្ធគ្នាទៅវិញទៅមក គឺពាក្យថា "គសប ធ្វើនយោបាយមិនចង់បានសន្លឹកឆ្នោត" និងពាក្យថា "នយោបាយគឺជាកិច្ចការរបស់អ្នកដែលចង់ជួយជាតិ" គសបសំដៅលើនិយមន័យខាងក្រោមនេះ។

"នយោបាយគឺជាសិល្បៈនៃការធ្វើបានសម្រេចគោលដៅ នៃការដឹកនាំរដ្ឋដោយមនោសុចរិត និងចាគៈប្រាស់ចាកភាពអាត្មានិយម"។ ក្នុងន័យនេះ នយោបាយមានន័យថា គឺជាសីលវិធីដែលគសបប្រើប្រាស់ដើម្បីឈានទៅសម្រេចគោលដៅជាបឋមរបស់ខ្លួន គឺការពន្យល់ប្រជាពលរដ្ឋអំពីសកម្មភាព ដើម្បីឈានទៅដាក់យន្តការប្រាំបីចំណុចជាច្បាប់អនុវត្ត និងដាក់ប្រព័ន្ធនៃការដឹកនាំរដ្ឋ ដោយអំណាចមិនប្រមូលផ្តុំនៅកម្ពុជា។ រាល់សកម្មភាពទាំងអស់ត្រូវធ្វើឡើងដោយបេះដូងជួយសង្គ្រោះ ហើយគ្មានចង់បានអ្វីជាប្រយោជន៍ផ្ទាល់ខ្លួនវិញនោះទេ។

គួរកត់សម្គាល់ថា អ្នកនយោបាយគឺជាអ្នកទាំងឡាយណា ដែលតួនាទី ឬមុខតំណែងរបស់គាត់ត្រូវបានជ្រើសរើសដោយការបោះឆ្នោតផ្ទាល់ ឬមិនផ្ទាល់ ឬដោយការចាត់តាំង ឲ្យទៅកាន់កិច្ចការរដ្ឋ ដោយអាណត្តិ។ តាមទ្រឹស្តី[1] មុខតំណែងនេះបានដល់ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលខេត្ត អភិបាលខេត្តរង អភិបាលស្រុក អភិបាលស្រុករង និងជំទប់ឃុំ។ មុខតំណែងមួយចំនួនទៀត នៅក្នុងស្ថាប័ន ដូចជា... ក៏ត្រូវបានបោះឆ្នោត និងតែងតាំងផងដែរ។

អត្ថបទនេះពន្យល់អំពីពាក្យគន្លឹះទាំងពីរនេះ ដើម្បីឆ្លើយបំភ្លឺបងប្អូនមួយចំនួន ទោះគាត់ជាគាំទ្រទស្សនវិស័យនៃការធ្វើនយោបាយរបស់គសបក្តី ឬមិនមែនជាអ្នកគាំទ្រគសបក្តី ដើម្បីឲ្យពួកគាត់យល់កាន់តែច្បាស់ថាតើ គសប យល់ឃើញយ៉ាងណា នៅពេលដែលខ្លួនថា "គសប ធ្វើនយោបាយមិនចង់បានសន្លឹកឆ្នោត" និងពាក្យថា "នយោបាយគឺជាកិច្ចការរបស់អ្នកដែលចង់ជួយជាតិ"។

ផ្តើមចេញពីបេះដូងជួយសង្គ្រោះ សកម្មភាពរបស់អ្នកនយោបាយត្រូវតែជាសកម្មភាពដែលធ្វើឡើងដោយមនោសុចរិតប្រាស់ចាកភាពអាត្មានិយម។ ខាងក្រោមនេះគឺជាហេតុផល ដែលអ្នកនយោបាយត្រូវតែ "ធ្វើនយោបាយដោយសុចរិត[2]" ដើម្បីធានាបាននូវការការគាំទ្រពីប្រជាពលរដ្ឋផង និងដើម្បីធ្វើឲ្យការអនុវត្តកម្មវិធីនយោបាយរបស់ខ្លួន បានជោគជ័យផង ក្រោយការបានទទួលសំឡេងគាំទ្រពីប្រជាពលរដ្ឋទៅបង្កើតរដ្ឋាភិបាល។

---

[1] តាមការអនុវត្តជាក់ស្តែង ក្រោមការដឹកនាំរបស់គណបក្សប្រជាជន ការតម្លើងឋានន្តរសក្តិមន្ត្រីរាជការតែងតែពាក់ព័ន្ធនឹងអតីតភាពរបស់មន្ត្រីនោះជាសមាជិកគណបក្សប្រជាជនធ្វើជាលក្ខណវិនិច្ឆ័យគោលសម្រាប់ការសម្រេច។

[2] ក្នុងចំណោមសុចរិតទាំងបី កាយ វាចារ និងចិត្ត ចិត្តសុចរិតគឺជាប្រធាន (មនោ បុព្វង្គមា ធម្មា)

១. នយោបាយគឺជាសកម្មភាពលះបង់ដោយបេះដូងជួយសង្គ្រោះ

គ្រប់អ្នកនយោបាយបានចូលរួមក្នុងសកម្មភាពនយោបាយរបស់ខ្លួន ដោយការស្ម័គ្រចិត្តរបស់ពួកខ្លួន និងដោយគ្មានការអំពាវនាវអង្វរករពីប្រជាពលរដ្ឋនោះទេ។ អ្នកនយោបាយនៅទីនេះសំដៅទៅដល់អ្នកដែលបានកាន់កិច្ចការស្រុកទេសតាមរយៈការបោះឆ្នោត ឬតាមរយៈការតែងតាំងផង និងសកម្មជនសំខាន់នៅក្នុងបក្សផ្សេងទៀត រួមទាំងគណបក្សប្រឆាំង ដែលអាចនឹងត្រូវទៅកាន់ការងារស្រុកទេសតាមរយៈការបោះឆ្នោត ឬការតែងតាំងនាពេលអនាគត។ ច្រកដែលពលរដ្ឋអាចក្លាយជាអ្នកនយោបាយគឺការចូលរួមជាមួយសកម្មភាពរបស់គណបក្សនយោបាយ។ ដោយសារការចូលរធ្វើនយោបាយគឺជាទង្វើជួយសង្គ្រោះ ដែលគ្មានការបង្ខិតបង្ខំ និងជាទង្វើដែលទទួលបានការទុកចិត្តពីប្រជាពលរដ្ឋតាមរយៈសន្លឹកឆ្នោត ឬការតែងតាំងពីមេបក្ស តាមរយៈជំនឿទុកចិត្តនោះ អ្នកនយោបាយត្រូវតែមានបេះដូងសុចរិតនិយាយតែការពិតអំពីទស្សនវិស័យ នៃសកម្មភាពនយោបាយរបស់ខ្លួន។ ទុច្ចរិតភាពរបស់អ្នកនយោបាយ តាមកាយក្តី វាចារក្តី និងចិត្តក្តី គឺជាការបោកប្រាស់ដែលមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុត ចំពោះប្រជាពលរដ្ឋ និងចំពោះប្រទេសជាតិទាំងមូល។

គសប បានប្រាប់ប្រជាពលរដ្ឋនៅតាមវេទិការនានា ដើម្បីឲ្យពួកគាត់ចេះអង្កេតមើលអំពីលក្ខណៈ ឬសណ្ឋានរបស់អ្នកនយោបាយដែលមិនមានសុចរិតភាពនៅក្នុងខ្លួន ដោយការយក "បេះដូងជួយសង្គ្រោះ" និង"ទស្សនវិស័យ" ធ្វើជាគោលសម្រាប់ផ្ទៀងផ្ទាត់។ នេះគឺជាសំណួរមួយចំនួនដែលបងប្អូនសួរដើម្បីដឹងថាតើអ្នកនយោបាយមានទស្សនវិស័យ ឬមានបេះដូងជួយសង្គ្រោះ ឬមិនមាន។

ដូច្នេះ នៅពេលពលរដ្ឋណាម្នាក់សម្រេចចិត្ត ចូលរួមក្នុងសកម្មភាពរបស់គណបក្ស ដើម្បីក្លាយខ្លួនជាអ្នកនយោបាយ ពលរដ្ឋផ្សេងទៀត ត្រូវតែអង្កេតទៅលើអ្នកដែលចង់ធ្វើអ្នកនយោបាយនោះ ថាតើគាត់មាន

- ចំណេះដឹងគ្រប់គ្រប់ ដើម្បីទៅបំពេញកិច្ចការដ៏សំខាន់សម្រាប់ជាតិ ហើយឬនៅ?
- ការប្តេជ្ញាចិត្តលះបង់ទាំងអាយុជីវិត ដើម្បីបុព្វហេតុនយោបាយរបស់ខ្លួន ហើយឬនៅ?
- ពេលវេលាគ្រប់គ្រាន់ ដើម្បីបំពេញកិច្ចការនយោបាយជាអាទិភាពនៅក្នុងជីវិត ហើយឬនៅ?
- មានបេះដូងបរិសុទ្ធទៅបំពេញកិច្ចការនយោបាយដោយមនោចាគៈប្រាស់ចាកភាពអាត្មានិយម ហើយឬនៅ?

ខាងក្រោមនេះគឺជាសូចនាករតូចៗ ដែលបងប្អូនអាចយកទៅផ្ទៀងមើលថា តើអ្នកនយោបាយដែលបងប្អូនបានគាំទ្រ ឬបម្រុងនឹងគាំទ្រ តាមរយៈឆ្នោតមួយសន្លឹករបស់បងប្អូន ជាអ្នកនយោបាយមានសណ្ឋានជាអ្នកនយោបាយសុចរិត ឬជាអ្នកនយោបាយទុច្ចរិត។ គួរកត់សម្គាល់ថា ទាំងនេះគឺជាការយល់ឃើញរបស់គសប ប៉ុណ្ណោះ ហើយវាមិនមែនជាទ្រឹស្តី ដែលបងប្អូនត្រូវតែប្រើជាដាច់ខាតនោះទេ។

# ភាពខុសគ្នារវាងនយោបាយសុចរិត និងនយោបាយទុច្ចរិត

| **ចរិតលក្ខណៈអ្នកនយោយបាយសុចរិត** | **ចរិតលក្ខណៈអ្នកនយោបាយទុច្ចរិត** |
|---|---|
| និយាយតិចតួចអំពីបញ្ហា ហើយយកចិត្តទុកដាក់លើ ដំណោះស្រាយជាងបញ្ហា | និយាយតែពីបញ្ហា ប៉ុន្តែគ្មានបង្ហាញដំណោះស្រាយឲ្យត្រូវបញ្ហា នោះទេ |
| ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយឥតលាក់លៀម | រុញការទទួលខុសត្រូវឲ្យអ្នកដទៃដោយឥតខ្មាសអៀន |
| ចាត់ទុកបញ្ហាជាឱកាសដើម្បីអភិវឌ្ឍខ្លួន | រអ៊ូរទាំអំពីបញ្ហា និងច្រណែនឈ្នានីស |
| ប្ដេជ្ញាចិត្ត ហើយបំពេញឲ្យខាងតែបាន | គ្រាន់តែសន្យា ហើយបំភ្លេចចោលវិញយ៉ាងងាយ |
| ត្រិះរិះរកមធ្យោបាយដើម្បីសម្រេចគោលដៅ | តែងតែរកលេះនេះលេះនោះគ្រប់បែបយ៉ាងដើម្បី លាក់បាំងភាពអសកម្មរបស់ខ្លួន |
| ប្រឈមនឹងការភ័យខ្លាច ហើយបំពេញការងារដើម្បីសម្រេច គោលដៅ | រស់នៅក្នុងភាពភ័យខ្លាច ព្រោះខ្លាចបាត់បង់ជីវិត |
| កំណត់គោលដៅច្បាស់លាស់សម្រាប់បុព្វហេតុជីវិត | គ្មានគោលដៅអ្វីសម្រាប់ជីវិតនោះទេ |
| បរិច្ចាកប្រយោជន៍ និងសេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ និងសេចក្ដីសុខអ្នកដទៃ | បំផ្លាញប្រយោជន៍ និងសេចក្ដីសុខអ្នកដទៃ ដើម្បីប្រយោជន និង សេចក្ដីសុខខ្លួនឯង |
| ឈឺច្អាល និងជួយដោះស្រាយបញ្ហាអ្នកដទៃ ដោយគ្មានចង់បាន អ្វីតបវិញ | រកសេចក្ដីសុខផ្ទាល់ខ្លួន លើគំនរទុក្ខអ្នកដទៃ |
| ចូលចិត្តស្ដាប់ ពិចារណា កត់ត្រានិងចែករំលែក | ចូលចិត្តជជែកយកតែឈ្នះគ្មានហេតុផល |
| ចំណាយលុយទិញចំណីសម្រាប់ខួរក្បាល | ចំណាយលុយទិញចំណីម្រាប់ក្រពះ និងការសប្បាយផ្ទាល់ខ្លួន |
| លើកតម្កើងវប្បធម៌នៃការចូលរួម ដោយការយល់ដឹង | បន្លំ និងសន្យាឲ្យមានការដើរតាមទាំងងងឹតងងុល |
| ប្រតិបត្តិមេរៀនព្រះពុទ្ធដើម្បីសេចក្ដីសុខបច្ចុប្បន្នជាតិ | ចាត់ទុក្ខមេរៀនព្រះពុទ្ធត្រឹមតែជាជំនឿ សាសនា ដើម្បីរក សេចក្ដីសុខជាតិក្រោយ |
| ចាត់ទុករឿងនយោបាយជារឿងរបស់ពលរដ្ឋគ្រប់រូប | ចាត់ទុកបញ្ហានយោបាយថាជាកិច្ចការរបស់អ្នកនយោបាយ តែប៉ុណ្ណោះ |
| ចាត់ទុកប្រជាពលរដ្ឋជាចលករដើម្បីដោះស្រាយបញ្ហាសង្គម | ចាត់ទុកឆន្ទៈរបស់អ្នកនយោយបាយជាយន្តការដោះស្រាយបញ្ហា |
| ចាត់ទុតួនាទីក្នុងនយោបាយជាការលះបង់ទាំងកម្លាំង ចំណេះដឹង និងថវិកា | ចាត់ទុកតួនាទីក្នុងនយោបាយជាមុខរបរចិញ្ចឹមជីវិតសុខស្រួល |
| កំណត់ចក្ខុវិស័យដោយប្រមុខដឹកនាំក្រុម និងកម្លាំងស្នូល ក្នុងចលនារបស់ខ្លួន | យករាស្ត្រដែលមានចំណេះដឹងតិចតួចធ្វើជាត្រីវិស័យ |
| ប្រើប្រាស់បេះដូងសុចរិតទៀងត្រង់ និងទស្សនវិស័យ ដើម្បីកៀងគរការចូលរួម | ប្រើប្រាស់ប្រជាប្រិយភាពពីអតិតកាល ឬពូជពង្សវង្សត្រកូលដើម្បីឲ្យប្រជាពលរដ្ឋស្រលាញ់ |
| បង្កើតចលនារួបរួមគ្នានៅលើមនោគមវិជ្ជានយោបាយដើម្បីស ង្គ្រោះជាតិ | ប្រើប្រាស់បុគ្គលដែលមានប្រជាប្រិយភាព ឬពូជពង្ស ដើម្បីគៀងគរពលរដ្ឋឲ្យដើរតាម |
| ពង្រឹងទំនុកចិត្តលើទង្វើរបស់ខ្លួនដោយការស្គាល់ខ្លួនឯងផង និងស្គាល់គូរប្រកួតផង | គិតតែរិះគន់គូរប្រកួត ដោយសារខ្លួនពុំមានទំនុកចិត្ត និយាយអួតអំពីខ្លួនឯង |
| ពន្យល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹង ដើម្បីបោះឆ្នោតគាំទ្រ ទស្សនរបស់ក្រុម | អួតអំពីខ្លួនឯងដើម្បីឲ្យប្រជាពលរដ្ឋបោះឆ្នោតគាំទ្រខ្លួនជាបុគ្គល |
| ឈ្នះលោកធម៌ទាំងប្រាំបី គឺ លាភ( អលាភ ) យស( អយស ) សរសើរ( និន្ទារ ) សុខ( ទុក្ខ ) | ឈ្នះលោកធម៌ទាំងប្រាំបី គឺ លាភ( អលាភ ) យស( អយស ) សរសើរ( និន្ទារ ) សុខ( ទុក្ខ ) |
| | |

បន្ទាប់ពីអានចរិតលក្ខណៈរបស់មនុស្សទាំងពីរក្រុមរួចមក បងប្អូនអាចចាប់ផ្ដើមវាយតម្លៃខ្លួនឯងជាមុនសិន ថាតើបងប្អូនស្ថិតការពិពណ៌នាមួយណា ដែលឆ្លុះបញ្ចាំងបងប្អូនត្រឹមត្រូវជាង មុននឹងបងប្អូនប្រើប្រាស់ចរិតលក្ខណៈទាំងនេះទៅវាយតម្លៃអ្នកដទៃ។ ប្រសិនបើបងប្អូនស្ថិតក្នុងប្រភេទពលរដ្ឋសុចរិត បងប្អូនមិនអាចទៅគាំទ្រអ្នកនយោបាយដែលមានចរិតមិនសុចរិតបាននោះទេ។

## ២. នយោបាយគឺជាសកម្មភាពរបស់ជនគំរូក្នុងសង្គម

អ្នកនយោបាយត្រូវតែជាជនគំរូនៅក្នុងគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល។ ទោះបីជាគ្មានមនុស្សល្អឥតខ្ចោះក្នុងសង្គមក៏ដោយ អ្នកនយោបាយត្រូវតែជាអ្នកដែលមានគុណសម្បត្តិច្រើនជាង និងមានគុរិបត្តិតិចជាងគេ បើប្រៀបធៀបទៅនឹងមនុស្សផ្សេងៗទៀត នៅក្នុងស្ថាប័ននោះ ឬមូលដ្ឋាននោះ។ ជនណាម្នាក់អាចក្លាយជាជនគំរូ ដើម្បីចូលរួមក្នុងសកម្មភាពនយោបាយ ទាល់តែជននោះមានលក្ខណៈសម្បត្តិដូចខាងក្រោម តាមការយល់ឃើញរបស់គសប។

ជនគំរូក្នុងកិច្ចការនយោបាយ ដែលត្រូវដោះស្រាយបញ្ហាសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ ហើយត្រូវបានគសបឲ្យតម្លៃខ្ពស់បំផុតគឺអ្នកដែលមានបេះដូងសុចរិតជួយសង្គ្រោះជាតិផង និងអ្នកដែលមានចំណេះដឹងទូទៅស្ដីពីបញ្ហាសង្គម និងជីវិតផង។ ពលរដ្ឋដែលមានលក្ខណៈសម្បត្តិទាំងពីរនេះមិនចាំបាច់ទាល់តែអ្នកមានកម្រិតវប្បធម៌ខ្ពស់ រហូតដល់ថ្នាក់បណ្ឌិត អនុបណ្ឌិតនោះទេ។ ជាការពិតណាស់ លក្ខណវិនិច្ឆ័យទាំងពីរនេះមានលក្ខណៈអរូបីយ៍ខ្លាំងណាស់ ហើយមិនអាចវាយតម្លៃដោយប្រជាពលរដ្ឋទូទៅតាមរយៈពាក្យសម្ដី និងសកម្មភាពរបស់អ្នកនយោបាយនោះទេ។ អ្នកនយោបាយទាំងអ្នកសុចរិត និងអ្នកទុចរិតអាចជាអ្នកពូកែនិយាយ និងមានសកម្មភាពហាក់បីដូចជាជួយសង្គ្រោះ ដូចគ្នា។ ប៉ុន្តែព្រះពុទ្ធមានព្រះបន្ទូលថា "មនោ បុព្វង្គមា ធម្មា" (ចិត្តគឺជាអ្នកបញ្ជាសកម្មភាពតាមកាយ និងវាចារ)។

ជនគំរូគឺជាជន ដែលលុះក្នុងធម៌ពីរក្នុងចំណោមធម៌ទាំងបី ដែលព្រះពុទ្ធបានសង្ខេបយ៉ាងខ្លី។ ទីមួយគាត់គឺជាអ្នកដែលមិនប្រព្រឹត្តអំពើអាក្រក់ (សព្វបាបស្ស អករណំ និងជាអ្នកធ្វើតែអំពើល្អ (កុសលស្សូបសម្បទា) ហើយអំពើល្អក្នុងន័យនេះគឺជា "អំពើចាគៈប្រាស់ចាកភាពអាត្មានិយម និងប្រកបដោយការយល់ដឹង"។ លក្ខណៈសម្បត្តិសម្គាល់ជនគំរូគឺជាអ្នកដែល**<u>វៀរចាកមិនប្រព្រឹត្ត</u>** "ឧប្បកិលេស១៦"ទាល់តែសោះ ឬ**<u>ប្រព្រឹត្តក្នុងកម្រិតតិចតួចបំផុត</u>** បើប្រៀបធៀបទៅនឹងមនុស្សក្នុងសហគមន៍របស់គាត់។ ឧបក្កិលេស ១៦ យ៉ាងគឺ

**១- អភិជ្ឈាវិសមលោភ:** សេចក្ដីលោភ ចង់បានហួសហេតុ បំពារបំពានរំលោភចង់បានតែរបស់គេ
**២- ទោសៈ** ប្រទូស ឬ បៀតបៀនគេ
**៣- កោធៈ** ក្រោធខឹង ធ្វើទុក្ខបុកម្នេញគេ
**៤- ឧបនាហៈ** ចងគំនុំ ឬ ចងក្រោធទុក
**៥- មក្ខៈ** លុបគុណ ឬ វេរឃ្មើរគុណគេ

៦- **បលាសៈ** វាយឫកស្មើ លើកតំកើងខ្លួន
៧- **ឥស្សា** ឫស្យាប្រណែនឈ្នានីសគេ
៨- **មច្ឆរិយៈ** កំណាញ់ស្វិតស្វាញ
៩- **មាយា** មានពុតត្បុតអាក្រក់ ឬ បិទបាំងទោសខ្លួន ហើយទម្លាក់ទៅលើអ្នកដទៃ
១០- **សាថេយ្យ** អួតអាង អែបបន្លំខ្លួន
១១- **ថម្ភៈ** កោងកាចព្រហើន ចចេសមុខរឹង
១២- **សារម្ភៈ** អួតថាគ្រាន់ ដណ្ដើមពូកែតែឯង
១៣- **មាន** ប្រកាន់ខ្លួន ឆ្មើងកន្ទ្រើង
១៤- **អតិមាន** មើលងាយគេ ប្រមាថបៀតបៀនគេ
១៥- **មទៈ** ស្រវឹងឈ្លក់ ក្នុងលាភ យស សុខ សរសើរ
១៦- **បមាទៈ** ធ្វេសប្រហែស ភ្លេចស្មារតី

នៅមុនពេលអ្នកចាប់យកអាជីពជាអ្នកនយោបាយ អ្នកត្រូវតែប្រាកដក្នុងចិត្តថា អ្នកគឺជាមនុស្ស ដែលវៀរចាកឧប្បកិលេសទាំង១៦ នេះ ហើយអ្នកពោរពេញទៅដោយ សារាណីយធម៌ទាំង៦ គឺ

*សារាណីយធម៌ ៦ យ៉ាងគឺ*
១- **មេត្តាកាយកម្ម** ការងារដែលត្រូវធ្វើការតាមផ្លូវកាយ សុទ្ធតែប្រកបដោយមេត្តា ឬ មេត្រីចិត្តដល់គ្នានិងគ្នា ។
២- **មេត្តាវចីកម្ម** កិច្ចការដែលត្រូវចាត់ចែងដោយសំដី សុទ្ធតែប្រកបដោយមេត្តា ។
៣- **មេត្តាមនោកម្ម** អំពើដែលធ្វើក្នុងចិត្ត សុទ្ធតែប្រកបដោយមេត្តា ។
៤- **លាភៈ** ការចែករំលែក លាភៈ យស សុខ សរសើរដល់គ្នា ។
៥- **សីលៈ** ដំណើរមានសណ្ដាប់ធ្នាប់ មានរបៀបបែបបទ និងសេចក្ដីប្រព្រឹត្តត្រូវគ្នា ។
៦- **ទិដ្ឋិ** សេចក្ដីយល់ត្រូវ ចុះសម្រុងគ្នា ឬ លទ្ធិត្រូវគ្នា ។

សម្រាប់ការជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារតាមក្រសួង មន្ទីរ និងការជ្រើសរើសបុគ្គលិកចូលបម្រើការងារក្នុងវិស័យឯកជន បេក្ខជនត្រូវឆ្លងកាត់ការប្រកួតប្រជែងដោយការធ្វើប្រឡងនានា ដោយគណៈកម្មធិការជ្រើសរើដែលជាទូទៅមានចំណេះដឹងជ្រៅជ្រះជាងបេក្ខជន ហើយអាចជ្រើសរើសបេក្ខជនបានត្រឹមត្រូវ។ ផ្ទុយទៅវិញ អ្នកនយោបាយត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋ ដែលភាគច្រើនជាអ្នកមានចំណេះដឹងតិចតួច តាមរយៈការបោះឆ្នោតសម្ដែងសេចក្ដីទុកចិត្ត។ ដោយមូលហេតុនេះ អ្នកនយោបាយត្រូវមានបេះដូងបរិសុទ្ធសម្បែងឲ្យប្រជាពលរដ្ឋបានដឹង ដើម្បីឲ្យពួកគាត់អាចជ្រើសរើសអ្នកដែលគាត់អាចគិតថា ទៅបម្រើគាត់បាន តាមរយៈគោលនយោបាយរបស់បក្សខ្លួន។

នៅក្នុងបរិបទកម្ពុជានាពេលនេះ ពលរដ្ឋបានបាត់បង់ជំនឿទុកចិត្តទៅលើអ្នកនយោបាយផង និងទៅលើប្រជាពលរដ្ឋផងគ្នាជាទូទៅផង។ ការបាត់បង់ការជឿជាក់លើគ្នាទៅវិញទៅមកនេះ គឺជាមហាគ្រោះថ្នាក់ចំពោះពលរដ្ឋខ្លួនឯងផង និងចំពោះប្រទេសជាតិទាំងមូលផង។ ការធ្វើនយោបាយ

ដោយសុចរិត ដើម្បីស្តារការជឿទុកចិត្តចំពោះអ្នកនយោបាយគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ដើម្បីស្តារការជឿទុកចិត្តរវាងគ្នាក្នុងចំណោមប្រជាពលរដ្ឋ។

## ៣. នយោបាយគឺជាសកម្មភាពប្រកួតប្រជែងទស្សនដឹកនាំដោយតម្លាភាព

សកម្មភាពនយោបាយគឺជាសកម្មភាពរបស់មួយក្រុមតូចក៏ពិតមែន ប៉ុន្តែវាជាសកម្មភាពដែលកំណត់ជោគវាសនារបស់ប្រទេសជាតិ និងប្រជាពលរដ្ឋទាំងមូល ជាពិសេសក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។ បើធ្វើត្រូវទំនង វាអាចនាំឲ្យជាតិរីកចម្រើន និងគង់វង្ស បើធ្វើខុសទំនង វាអាចនាំឲ្យជាតិអន្តរាយ ឬបាត់បង់ជាតិសាសន៍ និងទឹកដីតែម្តង។

ដោយសារស្ថានភាពបែបនេះ វាគ្មានហេតុផលអ្វី ដែលគណបក្សនយោបាយត្រូវលាក់លៀមអំពីសកម្មភាពនៃការធ្វើនយោបាយរបស់ខ្លួននោះទេ។ គណបក្សទាំងអស់ រួមទាំងគណបក្សកាន់អំណាចផង គួរតែបង្កលក្ខណៈងាយស្រួលឲ្យគណបក្សផ្សេងៗទៀត អាចបង្ហាញទស្សនវិស័យនៃការធ្វើនយោបាយរបស់ខ្លួន ទៅដល់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសឲ្យបានទូលំទូលាយជាប់ជាប្រចាំ។

ការផ្តល់ឱកាសឲ្យគណបក្សផ្សេងៗធ្វើនយោបាយដោយតម្លាភាព តាមរយៈការបង្ហាញប្រជាពលរដ្ឋអំពីខ្លឹមសារគោលនយោបាយ និងរបៀបដែលគណបក្សទាំងនោះផ្សព្វផ្សាយ ដើម្បីគៀងគរប្រជាពលរដ្ឋឲ្យគាំទ្រខ្លួនគឺជាការចាំបាច់ ដើម្បីឲ្យប្រជាពលរដ្ឋទទួលខុសត្រូវចំពោះជោគវាសនាប្រទេសជាតិផង នៅពេលប្រជាពលរដ្ឋបោះឆ្នោតគាំទ្រ និងដើម្បីធានាសមភាពនៃតទល់គ្នារវាងគណបក្ស និងគណបក្ស ដូចដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់។

តម្លាភាពគឺជាធាតុផ្សំចាំបាច់ដើម្បីទប់ស្កាត់មនុស្សទុច្ចរិតមិនឲ្យចូលប្រឡូកក្នុងនយោបាយផង និងដើម្បីជាមធ្យោបាយឲ្យប្រជាពលរដ្ឋអាចវាយតម្លៃ ថាតើអ្នកណាជាអ្នកមានបេះដូងសុចរិត និងជាជនគំរូ ដែលសក្តិសមនឹងដឹកនាំពួកគាត់ផង។

យន្តការដើម្បីធានាតម្លាភាពក្នុងសកម្មភាពនយោបាយគឺការផ្សព្វផ្សាយ ការជជែកដេញដោលរវាងតំណាងគណបក្ស និងប្រជាពលរដ្ឋ ឬការជជែកដេញដោលរវាងគណបក្ស និងគណបក្ស នៅតាមប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស តាមការបោះបុម្ព ឬតាមវេទិកាសាធារណៈ។ គោលបំណងនៃការជជែកដេញដោលគឺ ដើម្បីស្វែងយល់អំពីខ្លឹមសារគោលនយោបាយរបស់បក្សផង និងដើម្បីស្ទង់មើលដួងចិត្តសុចរិត ឬទុច្ចរិតរបស់ប្រមុខដឹកនាំគណបក្សនយោបាយនោះផង។

ជាលទ្ធផលនៃសកម្មភាពដើម្បីឆ្លុះបញ្ចាំងតម្លាភាពរបស់គណបក្សនយោបាយ ប្រជាពលរដ្ឋក៏បានដឹងយ៉ាងច្បាស់អំពីគោលនយោបាយរបស់គណបក្សនីមួយៗ ដឹងអំពីគោលបំណងនៃការធ្វើនយោបាយរបស់អ្នកនយោបាយ និងអំពីទីកន្លែងដែលគណបក្សនោះចង់នាំប្រជាពលរដ្ឋទៅ។ ដោយការយល់ដឹងទាំងអស់ប្រជាពលរដ្ឋអាចធ្វើការសម្រេចចិត្តជ្រើសរើសគណបក្ស ដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់។

នេះគឺជាបដិវត្តស៊ីជម្រៅផ្លាស់ប្តូរពីការបោះឆ្នោតដោះដូរ ដឹងគុណ និងអាណិតស្រលាញ់មកជាការបោះឆ្នោត ដោយការយល់ដឹង និងការទទួលខុសត្រូវ។

សរុបមក នយោបាយគឺជាសកម្មភាពនៃការប្រកួតប្រជែងទស្សនវាងគណបក្សនយោបាយមួយជាមួយគណបក្សនយោបាយមួយទៀត ឬច្រើនទៀត ដោយមានប្រជាពលរដ្ឋជាអ្នកសម្រេចសេចក្តីតាមរយៈឆ្នោតមួយសន្លឹករបស់ពួកគាត់។ ក្នុងនាមជាម្ចាស់ប្រទេស ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ដើម្បីស្វែងយល់អំពីគណបក្សនយោបាយនីមួយៗ។ ដូច្នេះ គណបក្សនីមួយៗត្រូវធ្វើសកម្មភាពនយោបាយរបស់ខ្លួនដោយតម្លាភាពជាទីបំផុត ដើម្បីឲ្យប្រជាពលរដ្ឋអាចសម្រេចបោះឆ្នោតជ្រើសរើសដែលខ្លួនគាំទ្រដោយមានព័ត៌មានគ្រប់គ្រាន់ ។ រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានត្រូវបង្កលក្ខណៈដើម្បីឲ្យដំណើរការប្រកួតប្រជែងទស្សនៈនយោបាយអាចប្រព្រឹត្តទៅបានដោយទូលំទូលាយ និងស្មើភាពគ្នា។

គណបក្សនយោបាយត្រូវតែចាប់ផ្តើមដើម្បីប្រកួតប្រជែងទស្សនៈនៃការធ្វើនយោបាយ ដោយការពិភាក្សាដេញដោល ដោយដួងចិត្តសុចរិត ដើម្បីចៀសវាងនូវការប្រឈមមុខគ្នា ដោយកម្លាំងបាយ ឬកម្លាំងចិត្តនៃការគុំគួន។ ផ្តើមចេញពីការប្រកួតប្រជែងទស្សនៈនេះ គណបក្សនយោបាយទាំងអស់ពិតជាអាចធ្វើការជាមួយគ្នាបាន ដោយ "តម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋ និងជាតិ" ធំជាងផលប្រយោជន៍គណបក្ស ឬផលប្រយោជន៍បុគ្គល។

សរុបសេចក្តីមក ការធ្វើនយោបាយគឺជាសកម្មភាពរបស់មនុស្សដែលចងក្រងគ្នាជាក្រុមៗ ដែលបានកំណត់សម្គាល់ឃើញបញ្ហាសង្គមដូចគ្នា មានទស្សនវិស័យដោះស្រាយបញ្ហានោះដូចគ្នា មានសណ្តានជាអ្នកឈឺឆ្អាលជួយសង្គ្រោះអ្នកដទៃឲ្យរួចផុតពីបញ្ហាដោយប្រាស់ចាកភាពអាត្មានិយម ដោយការប្រើប្រាស់មនោគមវិជ្ជានៃការធ្វើនយោបាយខុសប្លែកពីគ្នា។ ផ្អែកលើការវិភាគនេះ គសប ចាត់ទុកថាសកម្មភាពពន្យល់ប្រជាពលរដ្ឋគឺជាសកម្មភាពនយោបាយរបស់ខ្លួន។ មនុស្សនៅក្នុងគសបគ្មានតម្លៃអ្វីនោះទេ សម្រាប់ប្រជាពលរដ្ឋ។ ស្រដៀងគ្នាដែរ ឆ្នោតមួយសន្លឹកមកពីអ្នកដែលមិនយល់អំពីទស្សនវិស័យនយោបាយរបស់គសប ក៏គ្មានន័យអ្វីសម្រាប់គសបនោះដែរ។ទស្សនវិស័យនៃការធ្វើនយោបាយរបស់គសប និងឆ្នោតមួយសន្លឹកដែលទម្លាក់ចូលក្នុងហិបឆ្នោតដោយការយល់ដឹងទើបមានតម្លៃសម្រាប់គសបផង និងសម្រាប់ប្រជាពលរដ្ឋក្នុងចលនារំដោះខ្លួនឲ្យរួចផុតពីបញ្ហា និងការបាត់បង់ជាតិសាសន៍ និងទឹកដី។ ដូច្នេះ ប្រជាពលរដ្ឋត្រូវតែមានការយល់ដឹងអំពីទស្សនវិស័យរបស់គសបជាមុនសិន ទើបពួកគាត់អាចគាំទ្រទស្សនៈនេះបាន។ សន្លឹកឆ្នោតគ្រាន់តែជាអនីសង្ស (ផលអម) ដែលបានមកពីទង្វើនៃការពន្យល់របស់គសបតែប៉ុណ្ណោះ។ មាតុភូមិនដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងនាមជាម្ចាស់គឺជាគោលដៅរបស់ គសប។ លាភសក្ការៈដែលសមាជិកគសបបានទទួលក្នុងនាមជាពលរដ្ឋកម្ពុជាមួយរូប ក៏គ្រាន់តែជាផលអមនៃសកម្មភាពនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។